**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២២-០០៥ ការ.ស.ល

ថ្ងៃ ចន្ទ ១កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០២២

**ជម្រាបមក**

**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** ការពង្រឹងសមត្ថភាពមន្ត្រី-បុគ្គលិកពីឥណទាន តាមរយៈការបណ្តុះបណ្តាល ដែលរៀបចំដោយវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ។

**យោង ៖** លិខិតលេខ ១៦៩/២១/២០២១ ចុះថ្ងៃពុធ ១៣រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ឲ្យបានជ្រាបថា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ កំពុងរៀបចំវគ្គសិក្សាពង្រឹងសមត្ថភាព ពាក់ព័ន្ធការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ ដែលវគ្គសិក្សានេះមាន ៣ កម្រិត គឺ៖ កម្រិត១ សម្រាប់មន្ត្រី-បុគ្គលិកផ្តល់ឥណទាននិងអនុវត្តផ្ទាល់ កម្រិត២ សម្រាប់មន្ត្រីប្រធានផ្នែកឬប្រធានសាខា និងកម្រិត៣ សម្រាប់មន្ត្រីជាន់ខ្ពស់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

ដោយពិនិត្យឃើញអំពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាពបុគ្គលិករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា សូមលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ចាត់បញ្ជូនមន្ត្រី-បុគ្គលិកចូលរួមក្នុងវគ្គសិក្សាកម្រិត១ និងកម្រិត២ ដែលជាវគ្គកាតព្វកិច្ច ដោយសារមន្ត្រី-បុគ្គលិកដែលស្ថិតក្នុងកម្រិតនេះ គឺមានទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន ដែលតម្រូវឲ្យមានសមត្ថភាពក្នុងការវិភាគឥណទាន ការផ្តល់ព័ត៌មាន និងកិច្ចគាំពារអតិថិជន។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកាជ្រាប និងចាត់បញ្ជូនមន្ត្រី-បុគ្គលិកចូលរួមវគ្គសិក្សាខាងលើតាមការគួរ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ និងការរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ ស្របតាមផែនការសកម្មភាពអាទិភាពដូចមានចែងក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**ត.ប. ទេសាភិបាល**

**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណរះ**

*ចម្លងជូន៖*

*- សមាគមធនាគារនៅកម្ពុជា*

*- សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា*